# ព័ត៌មានសំខាន់សម្រាប់អ្នកដែលធ្វើជាអ្នកផ្ដល់សេវានៅពេលអនាគត ស្ដីអំពីដំណើរការនៃការចុះឈ្មោះធ្វើជាអ្នកផ្ដល់សេវានៅក្នុង កម្មវិធីសេវាការមើលថែទាំក្នុងផ្ទះ (IHSS)

អ្នកផ្ដល់សេវានៃ IHSS គឺជាជនណាម្នាក់ ដែលទទួលប្រាក់បង់ សម្រាប់កិច្ចការផ្ដល់សេវាដល់មនុស្សម្នាក់ ដែលទទួលសេវាការមើលថែទាំក្នុងផ្ទះ ក្រោមកម្មវិធី IHSS ។ ប្រសិនបើ អ្នកមានបំណងចង់ក្លាយទៅជាអ្នកផ្ដល់សេវានៃ IHSS, អ្នកត្រូវតែបំពេញជំណាក់ការទាំងអស់ ដែលមានចុះរាយនៅក្នុងគម្រោងខាងក្រោមនេះនៅក្នុងអំឡុងពេល <u>90 ថ្ងៃ</u> ពីថ្ងៃដែលអ្នកបានចាប់ផ្ដើមដំណើរការ មុននឹងអ្នកអាចត្រូវបានចុះឈ្មោះធ្វើជាអ្នកផ្ដល់សេវា និង ទទួលប្រាក់បង់ពីកម្មវិធី IHSS សម្រាប់កិច្ចការផ្ដល់សេវាបាន ។ ជំណាក់ការទាំងអស់នេះ មិនចាំបាច់ធ្វើតាមលំដាប់លំដោយជាពិសេសទេ ។ ប្រសិនបើអ្នកគិតថា អ្នកមានការចាប់ខ្លួន និង/ឬ ការផ្ដន្ទាទោសក្នុងបទឧក្រិដ្ឋ នៅក្នុងរយៈពេលដប់ឆ្នាំមុន មិនគិតថាជារឿងតូចតាចឬយ៉ាងណា អ្នកគួរតែចាប់ផ្ដើមដំណើរការ នៅជំណាក់ការទី 2 ពីព្រោះអ្នកមានពេលតែ 90 ថ្ងៃប៉ុណ្ណោះ ដើម្បីបំពេញជំណាក់ការទាំងអស់នោះ ហើយ វាត្រូវប្រើពេលយូរសម្រាប់ឱ្យក្រសួងយុត្តិធម៌ (DOJ) នៃរដ្ឋកាលីហ្វ័រនីញ៉ា ដើម្បីពិនិត្យបញ្ជាក់នៅក្នុងដំណើរការឆ្លងកាត់ការឆែកសារតាឧក្រិដ្ឋកម្មរបស់អ្នក និង ផ្ដល់ជូនខោនធីនូវព័ត៌មានអំពីបញ្ជីអ្នកប្រព្រឹត្តបទល្មើសទោសព្រហ្មទណ្ឌ របស់អ្នក ។

**ជំណាក់ការទី 1. បំពេញ និងចុះហត្ថលេខានៅលើសំណៅចុះឈ្មោះអ្នកផ្ដល់សេវាការមើលថែទាំក្នុងផ្ទះនៃកម្មវិធី IHSS (SOC 426) និង យកវាមកប្រគល់ឱ្យគេដោយផ្ទាល់នៅការិយាល័យ IHSS ខោនធី ឬអាជ្ញាធរសាធារណៈផ្នែក IHSS ។**

- យកសំណៅចម្លង SOC 426 ដែលពុំទាន់សរសេរមួយ ពីការិយាល័យ IHSS ខោនធី ឬ អាជ្ញាធរសាធារណៈផ្នែក IHSS ។ *សូមមើលព័ត៌មានដោយប្រុងប្រយ័ត្ន មុននឹងអ្នកបំពេញសំណៅនោះ ។*
- បំពេញសំណៅ SOC 426 និង ឆ្លើយនូវសំណួរទាំងអស់ឱ្យបានចប់សព្វគ្រប់ និង ដោយត្រឹមត្រូវតាមសេចក្ដីពិត ។ អ្នក<u>**ត្រូវធ្វើសេចក្ដីរាយការណ៍ឱ្យគេ**</u> ប្រសិនបើ អ្នកត្រូវបានជាប់ទោសក្នុងបទឧក្រិដ្ឋណាមួយ ដែលនឹងមិនអនុញ្ញាតឱ្យអ្នកធ្វើកិច្ចការជាអ្នកផ្ដល់សេវាបាន ។
- យកមកជាមួយនូវកាតសំគាល់ខ្លួនមានរូបថតដែលមានសុពលភាព ដែលចេញឱ្យដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ឬ ទីភ្នាក់ងារដែលគាំទ្រដោយរដ្ឋាភិបាលរដ្ឋ ឬដោយអង្គការនៃកុលសម្ព័ន្ធ ជនជាតិដើមអាមេរិកាំង ឬ ជនជាតិដើមអាឡាស្កា ដែលបានទទួលស្គាល់ដោយរដ្ឋាភិបាលសហព័ន្ធ <u>**ហើយនិង**</u> កាតសូស្សាល់សឺគូរីទី ច្បាប់ដើម ឬ កាតជំនួសដែលមានសំបុត្រចេញដោយនាយកដ្ឋានសូស្សាល់សឺគូរីទី ។
- ព័ត៌មានដែលអ្នកផ្ដល់នៅលើសំណៅ SOC 426 នឹងត្រូវយកមកពិនិត្យបញ្ជាក់នៅក្នុងដំណើរការឆ្លងកាត់ការឆែកសារតាឧក្រិដ្ឋកម្មដោយក្រសួងយុត្តិធម៌ (DOJ) ។

**ជំណាក់ការទី 2. បំពេញដំណើរការ ការផ្ដិតម្រាមដៃ និង ឆ្លងកាត់ដំណើរការ ការឆែកសារតាឧក្រិដ្ឋកម្មដោយក្រសួងយុត្តិធម៌នៃរដ្ឋកាលីហ្វ័រនីញ៉ា ។**

- ការិយាល័យ IHSS ខោនធី ឬអាជ្ញាធរសាធារណៈនឹងផ្ដល់ការណែនាំអំពីរបៀបបំពេញដំណើរការ ការផ្ដិតម្រាមដៃ ។ *សូមកុំព្យាយាមធ្វើការផ្ដិតម្រាមដៃឱ្យសោះ រហូតទាល់តែ អ្នកបានទទួលការណែនាំផ្សេងៗពីខោនធី ។*
- អ្នកអាចបំពេញដំណើរការ ការផ្ដិតម្រាមដៃ នៅទីភ្នាក់ងារមានសមត្ថកិច្ចនៅក្នុងតំបន់ខ្លះទៀត ដូចជា (ក្រសួងទីភ្នាក់ងារប៉ូលីស ឬក្រសួងតម្រួត) ឬ នៅស្ថាប័នជំនួញ ដែលផ្ដល់សេវាការផ្ដិតម្រាមដៃ ដែលពិនិត្យថតដោយម៉ាស៊ីនឌីជីថល (ម៉ាស៊ីនថតយករូបភាពពីរាងកាយ) ។ ការិយាល័យ IHSS ខោនធី ឬអាជ្ញាធរសាធារណៈ អាចផ្ដល់ជូនអ្នកនូវបញ្ជីរាយឈ្មោះនៃទីតាំងដែលនៅជិតកន្លែងអ្នករស់នៅ ។

- ច្បាប់រដ្ឋតម្រូវថា អ្នកត្រូវបង់ថ្លៃសម្រាប់ការផ្តិតម្រាមដៃ និង ដំណើរការឆ្លងកាត់ការឆែកសារតាឧក្រិដ្ឋកម្ម ។ ថ្លៃផ្តិតម្រាមដៃ គឺមានតម្លៃខុសៗគ្នា អាស្រ័យទៅលើទីកន្លែងដែលអ្នកជ្រើសយកការផ្តិតម្រាមដៃ ។ ការផ្តិតម្រាមដៃ មានតម្លៃពី $40 ទៅ $90 ។
- ប្រសិនបើ ដំណើរការឆ្លងកាត់ការឆែកសារតាពីអតីតបញ្ជាក់ថា អ្នក**<u>ត្រូវបានជាប់ទោស</u>**ក្នុងបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1 ឬ បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ណាមួយនោះ សូមមើលផ្នែកដែលទាក់ទងនឹងច្បាប់ទាំងអស់ ដែលមាននៅខាងក្រោម ហើយនឹងមាននៅទំព័របន្ទាប់ ។

ប្រសិនបើ អ្នក**ត្រូវបានគេ**ផ្តន្ទាទោស **ឬ** ត្រូវបានជាប់ពន្ធនាគារ បន្ទាប់ពីការដាក់ទោសសម្រាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1 ឬ បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 **នៅក្នុងអំឡុងពេល 10 ឆ្នាំកន្លងផុតទៅនោះ** អ្នក**<u>មិន</u>**មានលក្ខណសម្បត្តិចុះឈ្មោះធ្វើជាអ្នកផ្តល់សេវានៃ IHSS ឬ ទទួលបានប្រាក់បង់ពីកម្មវិធី IHSS សម្រាប់កិច្ចការផ្តល់សេវាការមើលថែទាំក្នុងផ្ទះបានឡើយ ។

| | |
|---|---|
| **<u>បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1</u> រួមមាន:**<br>• ការរំលោភបំពានលើកូនក្មេង ដែលបានកំណត់បញ្ជាក់នៅក្នុង (ច្បាប់ព្រហ្មទណ្ឌ (PC) វគ្គលេខ 273a(a);<br>• ការរំលោភបំពានលើមនុស្សចាស់ ឬមនុស្សពេញវ័យនៅក្នុងបន្ទុក ដែលបានចែងនៅក្នុង (ច្បាប់ព្រហ្មទណ្ឌ (PC) វគ្គលេខ 368); ឬ<br>• ការគៃបន្លំលើកម្មវិធីថែទាំសុខភាព ឬ សេវាសុខភាពដែលឧបត្ថម្ភដោយថវិការដ្ឋ ។ | ប្រសិនបើ អ្នកត្រូវបានផ្តន្ទាទោសក្នុង**បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1** នៅក្នុងអំឡុងពេល 10 ឆ្នាំកន្លងផុតទៅនោះ អ្នក**<u>មិន</u>**មានលក្ខណសម្បត្តិធ្វើជាអ្នកផ្តល់សេវាបានទេ ។<br>• អ្នក**<u>មិន</u>**មានលក្ខណសម្បត្តិចុះឈ្មោះធ្វើជាអ្នកផ្តល់សេវាបានទេ ទោះបីជា អ្នកមានបទល្មើសព្រហ្មទណ្ឌ**ថ្នាក់ទី 1** ដែលបានលុបចោលពីបញ្ជីឧក្រិដ្ឋកម្មរបស់អ្នកក៏ដោយ ។ |
| **<u>បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2</u> រួមមាន:**<br>• បទឧក្រិដ្ឋដ៏ឃោឃៅ ឬដ៏ធ្ងន់ធ្ងរ ដែលបានកំណត់បញ្ជាក់នៅក្នុងច្បាប់ព្រហ្មទណ្ឌ វគ្គលេខ 667.5(c), និង ច្បាប់ព្រហ្មទណ្ឌ វគ្គលេខ 1192.7(c),<br>• បទឧក្រិដ្ឋដែលមនុស្សម្នាក់តម្រូវឱ្យចុះក្នុងបញ្ជីឈ្មោះជាអ្នកប្រព្រឹត្តល្មើសលើភេទ ដោយអនុលោមទៅតាមច្បាប់ព្រហ្មទណ្ឌ វគ្គលេខ 290(c); និង<br>• បទឧក្រិដ្ឋក្នុងការគៃបន្លំប្រាក់ជំនួយនៃកម្មវិធីសេវាសង្គមកិច្ចសាធារណៈ ដូចដែលបានបញ្ជាក់នៅក្នុងបទបញ្ជាច្បាប់វែលហ្វែរនិងស្ថាប័ន (Welfare & Institutions Code) វគ្គលេខ 10980(c)(2) និង 10980(g)(2) ។<br><br>*អ្នកអាចស្នើសុំបញ្ជីរាយឈ្មោះបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2 ពីការិយាល័យ IHSS ខោនធី ឬអាជ្ញាធរសាធារណៈផ្នែក IHSS បាន។* | ប្រសិនបើ អ្នកត្រូវបានផ្តន្ទាទោសក្នុង**បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2** នៅក្នុងអំឡុងពេល 10 ឆ្នាំកន្លងផុតទៅនោះ អ្នកប្រហែលជាអាចមានលក្ខណសម្បត្តិធ្វើជាអ្នកផ្តល់សេវា:<br>• ប្រសិនបើ បទល្មើសព្រហ្មទណ្ឌ**ថ្នាក់ទី 2** របស់អ្នកត្រូវបាន ឬ អាចត្រូវបានលុបចោលពីបញ្ជីឧក្រិដ្ឋកម្មរបស់អ្នក ។<br>• ប្រសិនបើ អ្នកទទួលជំនួយស្នើសុំការលះបង់សិទ្ធិផ្ទាល់ខ្លួនដើម្បីជួលរូបអ្នក ។<br>• ប្រសិនបើ អ្នកត្រូវបានទទួលការយល់ព្រមសម្រាប់ការលើកលែងជាទូទៅ ។<br><br>*សូមមើលផ្នែកខាងក្រោមសម្រាប់ព័ត៌មានបន្ថែម ។* |

## <u>ការលុបចោលសម្រាប់បទឧក្រិដ្ឋថ្នាក់ទី 2:</u>

- ប្រសិនបើ អ្នកទទួលបានលិខិតស្តានីតិសម្បទាឡើងវិញ ឬលិខិតនៃការលុបចោលសម្រាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2, អ្នកប្រហែលជាអាចមានលក្ខណសម្បត្តិ ដើម្បីធ្វើជាអ្នកផ្តល់សេវានៃ IHSS បាន ។ សូមផ្តល់នូវលិខិតចម្លងស្តានីតិសម្បទាឡើងវិញ ឬ ឯកសារចម្លងស្តីអំពីការលុបចោល មកជាមួយនឹងសំណៅ SOC 426 ដែលអ្នកបានបំពេញចប់សព្វគ្រប់ ។

- ប្រសិនបើ អ្នកកំពុងតែនៅក្នុងដំណើរការនៃការលុបចោលបទឧក្រិដ្ឋ អ្នកគួរតែបំពេញដំណើរការនៃការលុបចោលនោះឱ្យបានចប់សព្វគ្រប់សិន មុននឹងអ្នកបន្តដំណើរការឆ្លងកាត់ការឆែកសារតាឧក្រិដ្ឋកម្ម ។

## ការលះបង់សិទ្ធិផ្ទាល់ខ្លួនក្នុងការមិនរាប់បញ្ចូលក្នុងការផ្តន្ទាទោសសម្រាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2:

ការលះបង់សិទ្ធិផ្ទាល់ខ្លួនអនុញ្ញាតឱ្យអ្នក ផ្តល់សេវាការមើលថែទាំក្នុងផ្ទះ សម្រាប់អ្នកទទួលជំនួយពិសេសម្នាក់ដែលជ្រើសជួលយកអ្នក ដើម្បីផ្តល់សេវាដល់រូបគេ **តែប៉ុណ្ណោះ** ទោះបីជា អ្នកត្រូវបានជាប់ទោសក្នុងបទឧក្រិដ្ឋ ក៏ដោយ ។

- អ្នកទទួលជំនួយត្រូវតែដាក់ពាក្យសុំ និង ផ្ញើសំណៅ (SOC 862) សេចក្តីស្នើសុំនៃអ្នកទទួលជំនួយក្នុងការលះបង់សិទ្ធិផ្ទាល់ខ្លួនសម្រាប់អ្នកផ្តល់សេវា ទៅការិយាល័យ IHSS ខោនធី ឬអាជ្ញាធរសាធារណៈ ដើម្បីអនុញ្ញាតឱ្យអ្នកបានធ្វើកិច្ចការជាអ្នកផ្តល់សេវាការមើលថែទាំក្នុងផ្ទះ ។

- អ្នកទទួលជំនួយ IHSS ដែលមានបំណងជួលអ្នក នឹងត្រូវគេប្រាប់អំពីការផ្តន្ទាទោសរបស់អ្នក; ទោះបីជាយ៉ាងណាក៏ដោយ គាត់/នាង នឹងត្រូវគេប្រាប់ដោយផ្ទាល់ឱ្យរក្សាទុក ព័ត៌មាននៃការជាប់ទោសក្នុងបទឧក្រិដ្ឋនេះ ជាការសម្ងាត់ ។

- ប្រសិនបើអ្នក ជាអ្នកផ្តល់សេវា គឺជាអ្នកតំណាងពេញច្បាប់របស់អ្នកទទួលជំនួយផងដែរនោះ អ្នក**មិន**ត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើការលើកលែង ក្នុងនាមតំណាងឱ្យអ្នកទទួលជំនួយ ដើម្បីលើកលែងបទឧក្រិដ្ឋទាំងឡាយណាដែលអ្នកត្រូវបានផ្តន្ទាទោសបានទេ ។ ក្នុងករណីនេះ ការលើកលែងត្រូវតែចុះហត្ថលេខាដោយផ្ទាល់ ដោយអ្នកទទួលជំនួយ ឬប្រសិនបើកិច្ចការនោះមិនអាចធ្វើទៅបាន មនុស្សម្នាក់ផ្សេងទៀតត្រូវតែបានប្រកាសថាជាអ្នកតំណាងពេញច្បាប់ ដើម្បីជាគោលបំណងនៃការចុះហត្ថលេខាលើការលើកលែងនេះ ។

ប្រសិនបើអ្នកទទួលជំនួយចុះហត្ថលេខាលើសំណៅការលះបង់សិទ្ធិផ្ទាល់ខ្លួន ដែលអនុញ្ញាតឱ្យអ្នកផ្តល់កិច្ចការសម្រាប់តែគាត់/នាងតែប៉ុណ្ណោះ និង គាត់/នាងបានរើទីលំនៅទៅនៅខោនធីផ្សេងមួយទៀត ឬ អ្នកសម្រេចចិត្តធ្វើការឱ្យអ្នកទទួលជំនួយម្នាក់ផ្សេងទៀតដែលរស់នៅក្នុងខោនធីមួយទៀត អ្នកនឹងត្រូវតែធ្វើការឆ្លងកាត់ដំណើរការឆែកសាវតាឧក្រិដ្ឋកម្ម នៅក្នុងខោនធីថ្មីនោះ ហើយ អ្នកទទួលជំនួយដែលអ្នកធ្វើការឱ្យនោះ នឹងត្រូវបំពេញ និងដាក់ស្នើពាក្យសុំមួយផ្សេងទៀត សម្រាប់ការលះបង់សិទ្ធិផ្ទាល់ខ្លួននៅក្នុងខោនធីថ្មីនោះ ។

## ការលើកលែងជាទូទៅសម្រាប់បទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2:

អ្នកដែលត្រូវគេរកឃើញថា មិនមានលក្ខណសម្បត្តិដើម្បីចុះឈ្មោះធ្វើជាអ្នកផ្តល់សេវា យោងទៅលើការជាប់ទោសក្នុងបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 2, តែ ដែលគេចង់មានឈ្មោះចុះនៅក្នុងបញ្ជីចុះឈ្មោះអ្នកផ្តល់សេវានោះ អាចដាក់ពាក្យសុំសម្រាប់ការបដិសេធលើការលើកលែងជាទូទៅមួយ ។

- ដាក់ពាក្យសុំសម្រាប់ការលើកលែកជាទូទៅ ដោយបំពេញសំណៅ (SOC 863) សេចក្តីស្នើសុំការលើកលែងជាទូទៅរបស់អ្នកដាក់ពាក្យសុំផ្តល់សេវានៃ IHSS ។

- អ្នកនឹងត្រូវគេតម្រូវឱ្យផ្តល់នូវឯកសារគាំទ្រនានា (ឧទាហរណ៍ ប្រវត្តិការងារ សំបុត្របញ្ជាក់ដែលយកជាសំអាង ។ល។) ដើម្បីគាំទ្រការស្នើសុំរបស់អ្នក សម្រាប់ការលើកលែងជាទូទៅ ។

ប្រសិនបើ អ្នកត្រូវបានដកហូតសិទ្ធិលែងមានលក្ខណសម្បត្តិធ្វើជាអ្នកផ្តល់សេវា យោងទៅលើការជាប់ទោសក្នុងបទល្មើសព្រហ្មទណ្ឌថ្នាក់ទី 1 ឬ ថ្នាក់ទី 2, អ្នកអាចស្នើសុំសំណៅចម្លងព័ត៌មានអំពីអ្នកប្រព្រឹត្តបទល្មើសទោសព្រហ្មទណ្ឌ (CORI) របស់អ្នកពីខោនធីបាន ។ សូមជំរាបឱ្យដឹងថា CORI អាចយកមកប្រើ សម្រាប់តែនៅក្នុងដំណើរការនៃការចុះឈ្មោះនេះ តែប៉ុណ្ណោះ ។

**ប្រសិនបើអ្នកគិតថា ព័ត៌មាននៅលើសាវតាឧក្រិដ្ឋកម្មរបស់អ្នក គឺមិនត្រឹមត្រូវទេនោះ អ្នកអាចទំនាក់ទំនងធ្វើការដោះស្រាយអំពីព័ត៌មាននេះ តាមរយៈដំណើរការឆ្លងកាត់ការពិនិត្យឡើងវិញនូវសំណុំរឿងពី ក្រសួងយុត្តិធម៌ (DOJ) ។**

ដំណើរការឆ្លងកាត់ការពិនិត្យឡើងវិញនូវសំណុំរឿងពីក្រសួងយុត្តិធម៌ (DOJ) មានរួមទាំងការដាក់ផ្ដិតម្រាមដៃ ការបង់ថ្លៃការចាត់ចែង និង ការធ្វើតាមការណែនាំដែលមាននៅលើគេហទំព័រ DOJ អាសយដ្ឋាន http://ag.ca.gov/fingerprints/security.php ។ ប្រសិនបើមានព័ត៌មានស្ដីអំពីបទឧក្រិដ្ឋនៅក្នុងបញ្ជីសំណុំរឿងរបស់អ្នក សំណុំបែបបទស្ដីអំពីបណ្ដឹងទាមទារសំណងនូវភាពមិនត្រឹមត្រូវឬមិនពិត ឬ ការមិនទាន់ចប់បរិបូរណ៍ (សំណៅ BCII 8706) នឹងត្រូវមានដាក់មកជាមួយនៅក្នុងការឆ្លើយតបនេះ ។

**ដំណាក់ការទី 3. ទៅចូលរួមក្នុងកម្មវិធី IHSS នៅក្នុងវគ្គណែនាំបង្ហាញលើកដំបូងសម្រាប់អ្នកផ្ដល់សេវា ដែលបានផ្ដល់ឱ្យដោយខោនធី**

- ការិយាល័យ IHSS ខោនធី ឬអាជ្ញាធរសាធារណៈនឹងជំរាបអ្នកឱ្យបានដឹង ពេលណា និង កន្លែងណាដែលអ្នកអាចទៅចូលរួមក្នុងវគ្គណែនាំបង្ហាញលើកដំបូង ។
- វគ្គណែនាំបង្ហាញលើកដំបូងនេះ នឹងផ្ដល់ជូនអ្នកនូវព័ត៌មានដ៏សំខាន់អំពីកម្មវិធី IHSS និង ច្បាប់ ហើយនិងសេចក្ដីតម្រូវទាំង អស់ដែលអ្នកត្រូវអនុវត្តតាម ដើម្បីធ្វើជាអ្នកផ្ដល់សេវា ។

**ដំណាក់ការទី 4. នៅចុងបញ្ចប់នៃវគ្គណែនាំបង្ហាញលើកដំបូង សូមចុះហត្ថលេខាលើសំណៅ (SOC 846) សេចក្ដីព្រមព្រៀងចុះឈ្មោះអ្នកផ្ដល់សេវាការមើលថែទាំក្នុងផ្ទះនៃកម្មវិធី IHSS ។**

- ដោយការចុះហត្ថលេខាលើសំណៅ SOC 846 នេះ អ្នកបានបញ្ជាក់ថា អ្នកយល់ និងយល់ព្រមអនុវត្តទៅតាមច្បាប់ និង សេចក្ដីតម្រូវទាំងអស់ សម្រាប់ធ្វើជាអ្នកផ្ដល់សេវានៅក្នុងកម្មវិធី IHSS ។

អ្នកគួរតែចម្លងទុកនូវឯកសារទាំងអស់ដែលអ្នកបានផ្ញើទៅឱ្យគេ និង សំបុត្រស្នាមណាមួយដែលអ្នកបានទទួលពីខោនធីដើម្បីទុកធ្វើជាកំណត់ត្រារបស់អ្នក ។

នៅពេលដែល អ្នកបានបំពេញដំណាក់ការទាំងបួន (4) ដំណាក់នេះប្រកបដោយជោគជ័យ និង ទទួលបានការយល់ព្រមពីខោនធី ឬអាជ្ញាធរសាធារណៈ ដើម្បីធ្វើជាអ្នកផ្ដល់សេវានៃ IHSS ដរាបណា អ្នកនៅតែជាអ្នកផ្ដល់សេវាសកម្ម ហើយការឆែកសាវតាឧក្រិដ្ឋកម្មរបស់អ្នក មានភាពជ្រះស្រឡះ អ្នកនឹងនៅតែមានលក្ខណសម្បត្តិទទួលកិច្ចការជាអ្នកផ្ដល់សេវាការមើលថែទាំក្នុងផ្ទះ សម្រាប់អ្នកទទួលជំនួយ IHSS ណាមួយបាន ។

**ប្រសិនបើ អ្នកមិនបានបំពេញដំណាក់ការទាំងបួន (4) ដំណាក់នេះ នៅក្នុងអំឡុងពេល 90 ថ្ងៃ បន្ទាប់ពីអ្នកបានចាប់ផ្ដើមដំណើរការចុះឈ្មោះធ្វើជាអ្នកផ្ដល់សេវា អ្នកនឹងត្រូវគេរកឃើញថាមិនមានលក្ខសម្បត្តិគ្រប់គ្រាន់នឹងធ្វើការ និង ទទួលបានប្រាក់បង់សម្រាប់ធ្វើជាអ្នកផ្ដល់សេវាបាននោះទេ ហើយនឹងតម្រូវឱ្យអ្នកចាប់ផ្ដើមដំណើរការនេះសារជាថ្មីម្ដងទៀត ដើម្បីឱ្យបានចុះឈ្មោះធ្វើជាអ្នកផ្ដល់សេវានៃ IHSS ។**

ប្រសិនបើអ្នកមានសំណួរណាមួយ អំពីសេចក្ដីតម្រូវទាំងនេះដើម្បីចុះឈ្មោះធ្វើជាអ្នកផ្ដល់សេវា សូមធ្វើការទាក់ទងទៅការិយាល័យ IHSS ខោនធី ឬអាជ្ញាធរសាធារណៈផ្នែក IHSS ។